# គណបក្ស សម រង្ស៊ី

**SAM RAINSY PARTY**
**PARTI SAM RAINSY**
**សីលធម៌ សច្ចធម៌ យុត្តិធម៌**

លេខ :......១៦៧.....ស.ណ.ន.គសរ
០៧/០៧

# សេចក្តីណែនាំ

## ស្តីពី

## ការកែសម្រួលនីតិវិធី និងបែបបទ នៃការបោះឆ្នោត ជ្រើសតាំងសមាជិក និងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង

### I_ការជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង

យោងចំណុច១-v និង៣-v នៃសេចក្តីណែនាំ ស្តីពី នីតិវិធី និងបែបបទនៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណបក្សភូមិ ឃុំ-សង្កាត់ ស្រុក-ខណ្ឌ និងខេត្ត-ក្រុង នីតិវិធីនៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបានកែសម្រួលដែលមានខ្លឹមសារដូចតទៅ :

ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងនីមួយៗ មានសមាជិកយ៉ាងតិចចំនួន១០រូប ។ គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ត្រូវកំណត់ចំនួនសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងនីមួយៗ ដែលត្រូវជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងមួយចំនួន ជាតំណាងគណបក្សស្រុក-ខណ្ឌ (ស្រុក-ខណ្ឌនីមួយៗមានតំណាងចំនួន០១រូប ទៅ០៣រូប តាមចំនួនប្រជាពលរដ្ឋនៃស្រុក-ខណ្ឌនោះ) ដែលជ្រើសតាំងដោយប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ និងសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌនីមួយៗ ហើយសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងមួយចំនួនទៀត ជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌទាំងឡាយនៃខេត្ត-ក្រុងសាមី ។ ចំនួនសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដែលជាតំណាងគណបក្សស្រុក-ខណ្ឌ មិនត្រូវឲ្យមានចំនួនស្មើ ឬច្រើនជាងចំនួនសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដែលជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌទាំងឡាយនៃខេត្ត-ក្រុងសាមីនោះទេ ។

បេក្ខជនឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងទាំងអស់ ដែលត្រូវបានស្នើ ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស (លើកលែងតែបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង) ម ានសិទ្ធិឈរឈ្មោះជាបេក្ខជនសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង តំណាងគណបក្សស្រុក-ខណ្ឌ ដែលសាមីខ្លួនពេញចិត្ត ។ បើបេក្ខជនរូបណាមិនត្រូវបានជ្រើសតាំងជាសមាជិកក្រុម



ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
**E-mail address :** srphq@online.com.kh, srpcabinet@online.com.kh, Website : samrainsyparty.org

ប្រឹក្សាគណបក្សខេត្ត-ក្រុង តំណាងឲ្យគណបក្សស្រុក-ខណ្ឌនោះទេ បេក្ខជនរូបនោះមានសិទ្ធិឈរឈ្មោះជាថ្មីទៀត ជាបេក្ខជនសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដែលជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌទាំងឡាយនៃខេត្ត-ក្រុងសាមី ។

ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងត្រូវរៀបចំជាពីរដំណាក់កាល :

១_ដំណាក់កាលទី១ : បោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដែលជាតំណាងគណបក្សស្រុក-ខណ្ឌ

គណៈកម្មការរៀបចំការបោះឆ្នោតត្រូវចុះឈ្មោះបេក្ខជន ដែលសុំឈរឈ្មោះជាបេក្ខភាពសមា-ជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង តំណាងស្រុក-ខណ្ឌនីមួយៗ នៅលើសន្លឹកឆ្នោតតាមលំដាប់លេខរៀងដែលបានចាប់ឆ្នោត ។ បន្ទាប់មក ប្រធានគណៈកម្មការបោះឆ្នោតត្រូវបង្ហាញបញ្ជីរាយនាមបេក្ខជនឈរឈ្មោះដល់អ្នកបោះឆ្នោត ។ ប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់នីមួយៗ និងសមា-ជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌសាមីដែលជាអ្នកបោះឆ្នោត មានសិទ្ធិគូសយកនូវបេក្ខជនណាដែលខ្លួនពេញចិត្ត ។ ឈ្មោះដែលទទួលបានការគាំទ្រនៅលើបញ្ជីរាយនាមបេក្ខជន មិនត្រូវមានចំនួនលើសពីចំនួនដែលត្រូវជ្រើសតាំង (បានកំណត់) នោះទេ ។ បើលើស សន្លឹកឆ្នោតនោះត្រូវចាត់ទុកជាមោឃៈ ។ បេក្ខជនរូបណាដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេពីការបោះឆ្នោតនឹងត្រូវជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង តំណាងគណបក្សស្រុក-ខណ្ឌ តាមលំដាប់លំដោយនៃចំនួនសម្លេងដែលបេក្ខជនម្នាក់ៗបានទទួល ។

២_ដំណាក់កាលទី២ : ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដែលជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌទាំងឡាយ នៃខេត្ត-ក្រុងសាមី

បន្ទាប់ពីរៀបចំការបោះឆ្នោតនៅក្នុងដំណាក់កាលទី១រួចហើយ គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវចុះឈ្មោះបេក្ខជនដែលមិនបានឈរឈ្មោះជាបេក្ខភាពសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង តំណាងឲ្យគណបក្សស្រុក-ខណ្ឌ និងបេក្ខជនដែលមិនបានជាប់ឆ្នោតក្នុងដំណាក់កាលទី១ ហើយយល់ព្រមមកប្រកួតប្រជែងជាថ្មីទៀត នៅលើសន្លឹកឆ្នោតតាមលំដាប់លេខរៀងដែលបានចាប់ឆ្នោត ។ បន្ទាប់មក ប្រធានគណៈកម្មការបោះឆ្នោតត្រូវបង្ហាញបញ្ជីរាយនាមបេក្ខជនឈរឈ្មោះដល់អ្នកបោះឆ្នោត ។ សមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌទាំងឡាយ ដែលជាអ្នកបោះឆ្នោតមានសិទ្ធិគូសយកនូវបេក្ខជនណាដែលខ្លួនពេញចិត្ត ។ ឈ្មោះដែលទទួលបានការគាំទ្រនៅលើបញ្ជីរាយនាមបេក្ខជន មិនត្រូវមានចំនួនលើសពីចំនួនដែលត្រូវជ្រើសតាំង (បានកំណត់) នោះទេ ។ បើលើស សន្លឹកឆ្នោតនោះត្រូវចាត់ទុកជាមោឃៈ ។ បេក្ខជនរូបណាដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេពីការបោះឆ្នោតនឹងត្រូវជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង តាមលំដាប់លំដោយនៃចំនួនសម្លេងដែលបេក្ខជនម្នាក់ៗបានទទួល ។

កិច្ចប្រជុំនៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ទាំងពីរដំណាក់-កាល យកជាការបានចាំបាច់ត្រូវមានកូរ៉ុម ៦ភាគ១០ នៃអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់ ។

ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដឹកនាំដោយគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងនោះ ។

## II_ការជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង

យោងចំណុច១ នៃសេចក្តីណែនាំ ស្តីពី បែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ការជ្រើសរើសបេក្ខជនក្រុមប្រឹក្សាឃុំ-សង្កាត់ និងបេក្ខជនតំណាងរាស្ត្រ នីតិវិធីនៃការបោះឆ្នោតជ្រើសតាំងប្រធានប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបានកែសម្រួលដែលមានខ្លឹមសារដូចតទៅ ៖

ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង សមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ និងប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់នៃខេត្ត-ក្រុងសាមី តាមរយៈការបោះឆ្នោតសម្ងាត់ដោយសម្លេងភាគច្រើនដាច់ខាតនៃអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់សំរាប់អាណត្តិ៣ឆ្នាំ ។ អាណត្តិរបស់ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបញ្ចប់នៅពេលដែលប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងថ្មីមកជំនួស ។

កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវកំណត់ដោយអគ្គលេខាធិការគណបក្ស យ៉ាងតិចមួយខែមុនផុតអាណត្តិ ។

កិច្ចប្រជុំនៃការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង យកជាការបានចាំបាច់ត្រូវមានកូរ៉ុម ៦ភាគ១០ នៃអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់ ។

ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង បំពេញការងាររបស់ខ្លួនយ៉ាងច្រើនពីរអាណត្តិនៅក្នុងខេត្ត-ក្រុងតែមួយ ។ ក្នុងករណីប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងរូបណាដែលដឹកនាំការងារគណបក្សឲ្យទទួលបានជ័យជំនះ ដោយអាសនៈសមាជិករដ្ឋសភានៅក្នុងខេត្ត-ក្រុងនោះកើនឡើង ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងរូបនោះ អាចឈរឈ្មោះជាបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងសាមីជាថ្មីទៀតបាន ។

### ១_សិទ្ធិឈរឈ្មោះជាបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង

សមាជិកសកម្មគណបក្ស ដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

_ជាសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដែលជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌទាំងឡាយនៃខេត្ត-ក្រុងសាមី ហើយជឿជាក់លើគោលការណ៍ និងគោលនយោបាយគណបក្ស មានកេរ្តិ៍ឈ្មោះល្អ មានសុភវិនិច្ឆ័យ ចូលរួមយ៉ាងសកម្មទាំងកម្លាំងកាយ ប្រាជ្ញា ថវិកា និងមានពេលវេលាជួយការងារគណបក្សខេត្ត-ក្រុងប្រកបដោយប្រសិទ្ធភាព ដូចជាដឹកនាំការងារគណបក្សខេត្ត-ក្រុង ឬស្រុក-ខណ្ឌឲ្យទទួលបានជោគជ័យក្នុងការបោះឆ្នោតឃុំ-សង្កាត់ ឬបោះឆ្នោតជាតិ

_មានកំរិតវប្បធម៌ថ្នាក់ឧត្តមសិក្សា ឬមានបទពិសោធន៍លើការងារគ្រប់គ្រង ដឹកនាំ និងយល់ដឹងទូលំទូលាយអំពីបញ្ហាសង្គម និងនយោបាយ ។

សមាជិកសកម្មគណបក្សរូបណា ដែលមានបំណងឈរឈ្មោះជាបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវដាក់ពាក្យសុំឈរឈ្មោះជាបេក្ខជន មកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស តាមរយៈអគ្គលេខាធិការគណបក្សយ៉ាងតិច១ខែមុនការបោះឆ្នោត ។ គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ត្រូវពិនិត្យ និងសំរេចលើពាក្យសុំនេះយ៉ាងតិច៥ថ្ងៃមុនថ្ងៃបោះឆ្នោត ។ ទំរង់បែបបទនៃពាក្យសុំឈរ

ឈ្មោះជាបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង កំណត់ដោយអគ្គលេខាធិការគណបក្ស ។

ក្នុងករណីដែលបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងណា មិនបានបំពេញតាមលក្ខខណ្ឌខាងលើ ប្រធានគណបក្សអាចស្នើសុំឲ្យសមាជិកមួយរូប ឬច្រើនរូប នៃក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងផ្សេងទៀត ទៅឈរឈ្មោះជាបេក្ខជនប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងនោះ ។

សមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងជាប់ឆ្នោត ដែលប្រកាសទទួលស្គាល់ដោយគណៈកម្មការរៀបចំការបោះឆ្នោត ឬទទួលស្គាល់ដោយប្រធានគណបក្ស សមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ និងប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់នៃខេត្ត-ក្រុងសាមី ដែលទទួលស្គាល់ដោយអគ្គលេខាធិការគណបក្ស មានសិទ្ធិចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងនោះ ។

ក្នុងករណីក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ណា ដែលមិនទាន់បានបោះឆ្នោតជ្រើសតាំងប្រធានថ្មីជំនួសប្រធានចាស់ដែលបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ ឬសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់នោះត្រូវជ្រើសតាំងតំណាងមួយរូប ពីក្នុងចំណោមសមាជិករបស់ខ្លួន ឲ្យមកចូលរួមបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ។ ឈ្មោះតំណាងដែលជ្រើសតាំងនេះត្រូវផ្តល់មកឲ្យគណៈកម្មការរៀបចំការបោះឆ្នោត យ៉ាងតិច០៣ថ្ងៃមុនថ្ងៃបោះឆ្នោត ។

បើលទ្ធផលនៃការបោះឆ្នោតនៅជុំទី១ ពុំមានបេក្ខជនណាមួយទទួលបានសម្លេងគាំទ្រជាប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង គណៈកម្មការរៀបចំការបោះឆ្នោតត្រូវរៀបចំការបោះឆ្នោតជុំទី២ ដោយជ្រើសរើសយកបេក្ខជនតែពីររូបដែលទទួលបានសម្លេងឆ្នោតច្រើនជាងគេទៅប្រកួតប្រជែង ។ ក្នុងករណីដែលបេក្ខជនទី២ និងទី៣ បានសម្លេងឆ្នោតស្មើគ្នា បើបេក្ខជននោះជាបុរស និងស្ត្រី អាទិភាពត្រូវបានទៅស្ត្រី, បើបេក្ខជននោះមានភេទដូចគ្នា ត្រូវធ្វើការចាប់ឆ្នោត ។

បើលទ្ធផលនៃការបោះឆ្នោតនៅជុំទី២នេះ ពុំមានបេក្ខជនណាមួយទទួលបានសម្លេងគាំទ្រភាគច្រើនដាច់ខាតនៃចំនួនអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវជ្រើសរើសយកបេក្ខជនមួយរូប ដែលទទួលបានសន្លឹកឆ្នោតច្រើនជាងគេ (ឬជ្រើសរើសយកបេក្ខជនស្ត្រី ឬវិធីចាប់ឆ្នោតបើភេទដូចគ្នា ក្នុងករណីបេក្ខជនទាំងពីររូបទទួលបានសម្លេងស្មើគ្នា) ទៅបោះឆ្នោតនៅជុំទី៣បន្តទៀត ។ នៅជុំទី៣នេះ បើបេក្ខជនរូបនោះពុំបានទទួលសម្លេងគាំទ្រជាប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងទេ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវលើកពេលនៃការបោះឆ្នោត ហើយធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ដើម្បីសុំគោលការណ៍សំរាប់ការបោះឆ្នោតលើកក្រោយ ។

## ២_ការគ្រប់គ្រងការបោះឆ្នោត

ការបោះឆ្នោតជ្រើសតាំងសមាជិក និងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវដឹកនាំដោយគណៈកម្មការរៀបចំការបោះឆ្នោតមួយ ដែលតែងតាំងដោយប្រធានគណបក្ស ។ ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោត គឺជាសមាជិកដែលមិនមែនជាបេក្ខជនឈរឈ្មោះប្រកួតប្រជែង យកតំណែងសមាជិក និងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងនោះ ។

គណៈកម្មការនេះ ត្រូវធានាដំណើរការ និងការប្រព្រឹត្តទៅនៃការរៀបចំការបោះឆ្នោត ឲ្យមានតម្លាភាព និងយុត្តិធម៌ ស្របតាមបទប្បញ្ញត្តិជាធរមានរបស់គណបក្ស ។

### ៣_ការប្តឹងជំទាស់លើលទ្ធផលនៃការបោះឆ្នោត :

#### ក_ការប្តឹងជំទាស់លើលទ្ធផលបឋម

បេក្ខជនសមាជិក ឬប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងរូបណា ដែលមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោតបឋមដោយមានហេតុផលច្បាស់លាស់ មានសិទ្ធិប្តឹងជំទាស់ភ្លាមជាលាយលក្ខណ៍អក្សរមកគណៈកម្មការរៀបចំការបោះឆ្នោត ។ គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវពិនិត្យនិងដោះស្រាយពាក្យបណ្តឹងភ្លាម បន្ទាប់ពីទទួលពាក្យបណ្តឹងជំទាស់ ។ បើរកឃើញថា ការបោះឆ្នោតនោះមានភាពមិនប្រក្រតីខុសនីតិវិធី គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវរៀបចំដំណើរការបោះឆ្នោតសារជាថ្មីឡើងវិញ ។ ផ្ទុយទៅវិញ បើគណៈកម្មការរៀបចំការបោះឆ្នោតពិនិត្យឃើញថាមិនមានកំហុសឆ្គង ឬភស្តុតាងណាមួយ ដែលនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវប្រកាសលទ្ធផលជាផ្លូវការ ដោយទុករយៈពេលបីថ្ងៃសំរាប់បើកផ្លូវតវ៉ាមកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

#### ខ_ការប្តឹងតវ៉ា

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ត្រូវដោះស្រាយវិវាទនៃការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងក្នុងរយៈពេលយ៉ាងយូរ៧ថ្ងៃបន្ទាប់ពីទទួលពាក្យបណ្តឹង ។ សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ជាសេចក្តីសំរេចចុងក្រោយបិទផ្លូវតវ៉ា ។

## III_ថវិកាសំរាប់រៀបចំការបោះឆ្នោត

ថវិកាសំរាប់ចំណាយក្នុងការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិក និងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវធានារ៉ាប់រងដោយបេក្ខជនឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដែលបេក្ខជនម្នាក់ៗត្រូវបង់ភាគទានយ៉ាងតិច១ភាគរយ នៃចំណាយសរុបក្នុងការរៀបចំការបោះឆ្នោត ។

ទុកជានិរាករណ៍ នូវសេចក្តីណែនាំទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីណែនាំខាងលើនេះ ។

សេចក្តីណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៧

ប្រធានគណបក្ស

សម រង្ស៊ី